ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសមាគមអតីតយុទ្ធជនកម្ពុជា

អនុម័តដោយ

មហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស លើកទី២

ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥

# សមាគមអតីតយុទ្ធជនកម្ពុជា

## បុព្វកថា

ប្រជាជនកម្ពុជាធ្លាប់មានប្រពៃណីតស៊ូអង់អាចក្លាហានប្រកបដោយស្មារតីស្នេហាជាតិខ្ពស់ ដើម្បីបុព្វហេតុឯករាជ្យជាតិ សង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ និងសន្តិភាព ។ ដើម្បីបុព្វហេតុជាតិមាតុភូមិអង្គរដ៏បវរ យុទ្ធជន យុទ្ធនារី ប្រជាជនជាច្រើនបានបូជាជីវិត រងរបួស ពិការ បាត់បង់សមត្ថភាពការងារ ប្រកបដោយវីរភាព ។ អតីតយុទ្ធជន ជាជនដែលមានគុណបំណាច់ចំពោះជាតិដែលរាជរដ្ឋាភិបាល និងសង្គមជាតិបានយកចិត្តទុកដាក់ផ្តល់កិត្តិយស ផ្តល់របបគោលនយោបាយសមស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ ព្រមទាំងជួយឧបត្ថម្ភស្មារតី និងសម្ភារ ។

សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាសប្រាំ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាវរជនដ៏ឆ្នើម ដែលបានលះបង់ដើម្បីបុព្វហេតុប្រទេសជាតិ និងប្រជាជន បានរួមចំណែកដឹកនាំចលនាតស៊ូសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ទទួលបានជោគជ័យជាប្រវត្តិសាស្ត្រ ថ្ងៃ ៧ មករា ១៩៧៩ បានដាក់ចេញ និងអនុវត្តដោយជោគជ័យនូវនយោបាយ ឈ្នះ ឈ្នះ នៅឆ្នាំ ១៩៩៨ ធ្វើឲ្យទឹកដីកម្ពុជាទាំងមូលបានឯកភាព សន្តិភាព ស្ថិរភាព បានដឹកនាំការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនលូតលាស់លើគ្រប់វិស័យ និងការពារបូរណភាពទឹកដីប្រឆាំងអំពើឈ្លានពានពីបរទេសទទួលបានជោគជ័យជាបន្តបន្ទាប់ ព្រមទាំងលើកស្ទួយកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាខ្ពស់ត្រដែតលើឆាកអន្តរជាតិ។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺជាស្ថាបនិកដែលបានផ្តួចផ្តើមបង្កើត និងធ្វើជាប្រធានដឹកនាំផ្ទាល់ចំពោះសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីលើកស្ទួយជីវភាព បង្កើតស្មារតីជួយឧបត្ថម្ភគ្នាទៅវិញទៅមកលើកកម្ពស់តួនាទីរបស់អតីតយុទ្ធជនឲ្យសក្តិសមនឹងគុណបំណាច់ចំពោះប្រទេសជាតិ និងប្រជាជន។

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

ប្រការ១.-

សមាគមអតីតយុទ្ធជនកម្ពុជា សរសេរជាអក្សរកាត់ "ស.អ.ក." សរសេរជាអក្សរអង់គ្លេស CAMBODIA VETERAN ASSOCIATION "C.V.A." ត្រូវបានបង្កើតឡើងដោយអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ។

ពាក្យថា "អតីតយុទ្ធជន" នៅក្នុងលក្ខន្តិកៈនេះសំដៅដល់ជនទាំងឡាយណាដែលធ្លាប់បានបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ហើយបានបញ្ចប់ការងាររបស់ខ្លួនត្រឹមត្រូវតាមច្បាប់។

ពាក្យថា "គ្រួសារអតីតយុទ្ធជន" សំដៅដល់ ឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ប្រពន្ធ ឬប្តី និង កូនបង្កើតរបស់អតីតយុទ្ធជន ។

ស.អ.ក. មានទីស្នាក់ការបណ្តោះអាសន្ននៅអគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ស.អ.ក. អាចផ្លាស់ប្តូរទីស្នាក់ការរបស់ខ្លួនតាមការចាំបាច់ដោយមានការសម្រេចពីគណៈអចិន្ត្រៃយ៍ ស.អ.ក. ។

ប្រការ២.-

គោលបំណង និងសកម្មភាពរបស់ ស.អ.ក. គឺដើម្បី៖

- លើកកម្ពស់កិត្តិយសឲ្យសក្តិសមនឹងគុណបំណាច់របស់អតីតយុទ្ធជនចំពោះបុព្វហេតុប្រទេសជាតិ
- ការពារសិទ្ធិ ផលប្រយោជន៍ និងលើកស្ទួយកម្រិតជីវភាពអតីតយុទ្ធជន
- បង្កើតស្មារតីសាមគ្គី ជួយគ្នាទៅវិញទៅមកក្នុងឋានៈជាសមាជិករបស់ ស.អ.ក. ពេលជួបការលំបាក គ្រោះថ្នាក់ មរណភាព ដោយមិនប្រកាន់ប្រភពដើម សាសនានិន្នាការនយោបាយ និង ឋានៈក្នុងសង្គមឡើយ ។

ប្រការ៣.-

ក-ស្លាកសញ្ញា ស.អ.ក. មានរាងមូល និងបែងចែកជា៖

- **រង្វង់ព័ទ្ធខាងក្រៅ:** មានពណ៌ខៀវចាស់ ផ្នែកខាងលើមានសរសេរអក្សរខ្មែរថា :
  **"សមាគមអតីតយុទ្ធជនកម្ពុជា"**
  ផ្នែកខាងក្រោមមានសរសេរអង់គ្លេសថា:
  "CAMBODIA VETERAN ASSOCIATION" ។
  អក្សរទាំងពីរ ខណ្ឌដោយក្បាច់ផ្កាច័ន្ទ ពណ៌លឿង ។
- **រង្វង់មូលខាងក្នុង:** -មានផ្ទៃពណ៌ផ្ទៃមេឃ មានរូបក្រាបគ្រជាងស្លាបពណ៌ប្រផេះ ពាំផ្កាចំប៉ា១ទងពណ៌ស ទំលើកងចក្រ ជាតំណាងឲ្យសន្តិភាព និងអតីតយុទ្ធជនកម្ពុជា ។
  -នៅខាងលើរូបក្រាប មានរូបប្រាសាទកំពូលបីពណ៌មាស ជានិមិត្តរូបប្រជាជាតិកម្ពុជាដ៏រុងរឿង ។
  -កម្រងកួរស្រូវពណ៌មាសចំនួន ៧៩ គ្រាប់ អមសងខាងជារង្វង់ស្វែងក្របី ជានិមិត្តរូបនៃវិស័យកសិកម្ម ដែលជាសេដ្ឋកិច្ចសំខាន់របស់ជាតិ ។
  -ខ្សែបូក្រហម រុំព័ទ្ធផ្នែកខាងក្រោមនៃកម្រងកួរស្រូវជាពីរថ្នាក់ សរសេរកាត់ជាអក្សរខ្មែរថា "**ស.អ.ក.**" និងសរសេរកាត់ជាអក្សរអង់គ្លេសថា "C.V.A." ។
  -កងចក្រ ៧ កាំ មានពណ៌ខៀវចាស់ នៅពីក្រោមរូបក្រាប ជានិមិត្តរូបនៃការអភិវឌ្ឍសេដ្ឋកិច្ចជឿនលឿនរបស់ជាតិ ។

ខ-ស.អ.ក. មានត្រារបស់ខ្លួនសម្រាប់ប្រើប្រាស់ ដែលមានគំរូត្រាជាឧបសម្ព័ន្ធនៃលក្ខន្តិកៈនេះ ។

ប្រការ៤.-

ទិវាអតីតយុទ្ធជន ត្រូវបានកំណត់យកថ្ងៃទី២១ខែមិថុនា ជារៀងរាល់ឆ្នាំ តាមសេចក្តីសម្រេចលេខ ៣១ ស.ស.រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ។

## ជំពូកទី២
## សមាជិកភាព

ប្រការ៥.-

សមាជិក ស.អ.ក.មានបីប្រភេទ ៖

១.សមាជិកកិត្តិយស : សមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឧកញ៉ា ឥស្សរជន កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងសប្បុរសជន ដែលបានឧបត្ថម្ភគាំទ្រដល់បុព្វហេតុការពារជាតិ និងការអភិវឌ្ឍអតីតយុទ្ធជន ។

២.សមាជិកសកម្ម : អតីតយុទ្ធជន ដែលជានិវត្តជន ជនពិការ ជនបាត់បង់សមត្ថភាពការងារ យោធិនរំសាយ និងមន្ត្រីបុគ្គលិកអង្គភាពកំចាត់មីន ។

៣.សមាជិកអកម្ម : គ្រួសារអតីតយុទ្ធជន ពលី មរណៈ ដែលស្ថិតក្នុងការគ្រប់គ្រង និងមានឈ្មោះជាម្ចាស់សៀវភៅរបបគោលនយោបាយ ដែលបើកផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ៦.-

សមាជិករបស់ ស.អ.ក. មានសិទ្ធិ និងភាតព្វកិច្ចដូចខាងក្រោម ៖

១. សមាជិកសកម្ម

ក-សិទ្ធិ

-ទទួលសេចក្តីសម្រេចបញ្ចូលសមាជិក
-ទទួលប័ណ្ណសម្គាល់ជាសមាជិក ១សន្លឹក
-ទទួលអត្ថប្រយោជន៍ផ្សេងៗតាមលក្ខន្តិកៈ និងគោលការណ៍របស់ ស.អ.ក.
-ទទួលបានព័ត៌មានស្តីពីសភាពការណ៍ប្រទេសជាតិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធ ទៅនឹងវិស័យអតីតយុទ្ធជន
-ចូលរួមផ្តល់យោបល់ និងពិភាក្សាលើកិច្ចការរបស់សមាគម
-បោះឆ្នោត ឈរឈ្មោះជាបេក្ខជន និងឧទ្ទេសនាមបេក្ខជនឈរឈ្មោះ សម្រាប់ជ្រើសតាំងជាថ្នាក់ដឹកនាំ ស.អ.ក. គ្រប់ជាន់ថ្នាក់
-មានសិទ្ធិស្នើសុំចូលជាសមាជិក បេឡាមរណសង្គ្រោះ ។

ខ-ភាតព្វកិច្ច

-គោរព និងប្រតិបត្តិតាមលក្ខន្តិកៈគោលការណ៍និងសេចក្តីសម្រេចរបស់ ស.អ.ក.
-បង់ភាគទានសមាជិកប្រចាំខែ តាមការកំណត់របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក.
-បង់ប្រាក់បេឡាមរណសង្គ្រោះតាមការកំណត់របស់ ស.អ.ក. (ចំពោះសមាជិកបេឡាមរណសង្គ្រោះ)
-ចូលរួមសកម្មភាពរបស់ ស.អ.ក. ក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន រួមចំណែកអភិវឌ្ឍប្រទេសជាតិ និងការការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

២.សមាជិកអកម្ម

សមាជិកអកម្មមានសិទ្ធិនិងកាតព្វកិច្ចដូចគ្នានឹងសមាជិកសកម្មដែរ ប៉ុន្តែពុំមានសិទ្ធិនិងកាតព្វកិច្ច៖

-បោះឆ្នោត ឈរឈ្មោះជាបេក្ខជន និងឧទ្ទេសនាមបេក្ខជនឈរឈ្មោះសម្រាប់ជ្រើសតាំងជាថ្នាក់ដឹកនាំ ស.អ.ក. គ្រប់ជាន់ថ្នាក់

-ស្នើសុំចូលជាសមាជិកបេឡាមរណសង្គ្រោះ

-បង់ប្រាក់បេឡាមរណសង្គ្រោះ។

៣.សមាជិកកិត្តិយស

សមាជិកកិត្តិយសមានសិទ្ធិនិងកាតព្វកិច្ចដូចគ្នានឹងសមាជិកសកម្មដែរ ប៉ុន្តែពុំមានសិទ្ធិនិងកាតព្វកិច្ច៖

-ទទួលអត្ថប្រយោជន៍ផ្សេងៗតាមលក្ខន្តិកៈ និងគោលការណ៍របស់ ស.អ.ក.

-បង់ប្រាក់ភាគទានប្រចាំខែ

-ស្នើសុំចូលជាសមាជិកបេឡាមរណសង្គ្រោះ

-ទទួលប្រាក់បេឡាមរណសង្គ្រោះ

សមាជិកកិត្តិយសមានកាតព្វកិច្ចបង់ប្រាក់វិភាគទាន ឬអំណោយសប្បុរសធម៌តាមសទ្ធាជូន ស.អ.ក. ។

ប្រការ៧.-

សមាជិក ស.អ.ក. មានចែងនៅក្នុងប្រការ ៥ត្រូវដាក់ពាក្យសុំចូលជាសមាជិក ស.អ.ក.។ បែបបទដែលត្រូវបំពេញមាន :

- ពាក្យសុំចូលសមាជិក ១ ច្បាប់
- ជីវប្រវត្តិសង្ខេប ១ ច្បាប់
- រូបថតបច្ចុប្បន្នភាព (៤x៦) ចំនួន ០៣ សន្លឹក។

ប្រការ៨.-

-សម្តេចប្រធាន ស.អ.ក. ចេញសេចក្តីសម្រេចទទួលស្គាល់សមាជិកកិត្តិយស តាមការស្នើសុំពីគណៈអចិន្ត្រៃយ៍ ស.អ.ក. ។ ប័ណ្ណសម្គាល់សមាជិកកិត្តិយស ស.អ.ក. ត្រូវចុះហត្ថលេខាដោយសម្តេចប្រធាន ស.អ.ក. ឬ អគ្គលេខាធិការ ស.អ.ក. តាមការប្រគល់សិទ្ធិ ។

-គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ និងចេញប័ណ្ណសម្គាល់សមាជិក ស.អ.ក. ដូចចែងក្នុងប្រការ ៥ ចំណុច២ និងចំណុច៣ ខាងលើតាមសំណើរបស់សាខា ស.អ.ក. ឃុំ សង្កាត់តាមរយៈគណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីមិនទាន់មាន ស.អ.ក. ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវចេញ សេចក្តីសម្រេចទទួលស្គាល់សមាជិក ស.អ.ក. យោងតាមពាក្យស្នើសុំចូលជាសមាជិក របស់សាមីជន។

ប្រការ៩.-

គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. នូវបញ្ជីរាយនាមសមាជិក ស.អ.ក. ដោយភ្ជាប់ជាមួយនូវសេចក្តីសម្រេចបញ្ចូលសមាជិក យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយពីមានការសម្រេចបញ្ចូលសមាជិកថ្មី ។

ប្រការ១០.-

សមាជិក ស.អ.ក. ដែលត្រូវផ្លាស់ប្តូរលំនៅឋាន ត្រូវបានរក្សាសមាជិកភាពដដែល ។ គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្តត្រូវធ្វើលិខិតផ្ទេរសមាជិកពីកន្លែងចាស់ ទៅកន្លែងថ្មីជូនទៅគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ដែលត្រូវគ្រប់គ្រងបន្ត។

ប្រការ១១.-

សមាជិក ស.អ.ក. អាចបាត់បង់សមាជិកភាពក្នុងករណីណាមួយដូចខាងក្រោម ៖

**១.ចំពោះសមាជិកសកម្ម**

-មិនបានបង់ប្រាក់ភាគទានសមាជិកភាព ៣(បី) ខែ ជាប់គ្នាដោយគ្មានមូលហេតុសមស្រប

-មិនបានបង់ប្រាក់បេឡាមរណសង្គ្រោះ ៣(បី) ខែ ជាប់គ្នាដោយគ្មានមូលហេតុសមស្រប (ក្នុងករណីជាសមាជិកបេឡាមរណសង្គ្រោះ)

-សមាជិកដែលត្រូវបានបណ្តេញចេញពី ស.អ.ក.

-សាមីខ្លួនស្នើសុំលាលែងពីសមាជិក ស.អ.ក.

-សាមីខ្លួនទទួលមរណភាព។

**២.ចំពោះសមាជិកអកម្ម**

-មិនបានបង់ប្រាក់ភាគទានសមាជិកភាព ៣(បី) ខែ ជាប់គ្នាដោយគ្មានមូលហេតុសមស្រប

-សមាជិកដែលត្រូវបានបណ្តេញចេញពី ស.អ.ក.

-សាមីខ្លួនស្នើសុំលាលែងពីសមាជិក ស.អ.ក.

-សាមីខ្លួនទទួលមរណភាព។

**៣.សមាជិកកិត្តិយស**

-សមាជិកដែលត្រូវបានបណ្តេញចេញពី ស.អ.ក.

-សាមីខ្លួនស្នើសុំលាលែងពីសមាជិក ស.អ.ក.

-សាមីខ្លួនទទួលមរណភាព។

សេចក្តីសម្រេចស្តីពីការបាត់បង់សមាជិកភាពរបស់សមាជិកកិត្តិយស ត្រូវធ្វើឡើងដោយសម្តេចប្រធាន ស.អ.ក. តាមការស្នើសុំពីគណៈអចិន្ត្រៃយ៍ ស.អ.ក.។

សេចក្តីសម្រេចស្តីពីការបាត់បង់សមាជិកភាពរបស់សមាជិកសកម្មនិងសមាជិកអកម្ម ស.អ.ក. ត្រូវធ្វើឡើងដោយគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ដែលចេញសេចក្តីសម្រេចទទួលស្គាល់សមាជិកភាព ។ គណៈកម្មាធិការ ស.អ.ក. ថ្នាក់ណាដែលចេញសេចក្តីសម្រេចត្រូវផ្ញើជូនគណៈអចិន្ត្រៃយ៍ ស.អ.ក. នូវបញ្ជីរាយនាមសមាជិក ស.អ.ក. ដែលបានបាត់បង់សមាជិកភាព ដោយភ្ជាប់ជាមួយនូវសេចក្តីសម្រេចស្តីពីការបាត់បង់សមាជិកភាពយ៉ាងយូរ ៣០(សាមសិប)ថ្ងៃបន្ទាប់ ពីមានការសម្រេច។

ប្រការ១២.-

ក្នុងករណីសមាជិក ស.អ.ក. បាត់បង់សមាជិកភាព ប្រាក់ភាគទានសមាជិកភាព ប្រាក់បេឡាមរណសង្គ្រោះប្រាក់វិភាគទានដែលបានបង់រួច ឬអំណោយសប្បុរសធម៌ និងអត្ថប្រយោជន៍ផ្សេងៗ ត្រូវទុកជាទ្រព្យសម្បត្តិរបស់ ស.អ.ក.។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

ប្រការ១៣.-

រចនាសម្ព័ន្ធរបស់ ស.អ.ក. មាន :

- គណៈកម្មាធិការកណ្តាល ស.អ.ក.
- គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត
- គណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ
- សាខា ស.អ.ក. ឃុំ សង្កាត់ ។

## ជំពូកទី៤
## មហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេស

ប្រការ១៤.-

មហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនទូទាំងប្រទេសជាស្ថាប័នដឹកនាំកំពូល ដែលត្រូវបានកោះប្រជុំជាសាមញ្ញ ៥ ឆ្នាំម្តង ។ ក្នុងករណីមានការស្នើសុំពីសមាជិកគណៈកម្មាធិការកណ្តាល ១ភាគ៣ ឬគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ដោយមានការយល់ព្រមពីសម្តេចប្រធាន មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់ ស.អ.ក. ត្រូវបានកោះប្រជុំ ។ មហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញមានតម្លៃដូចគ្នា។

ប្រការ១៥.-

ភារកិច្ចរបស់មហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេសឬមហាសន្និបាតវិសាមញ្ញតំណាង ស.អ.ក. ទូទាំងប្រទេសគឺ:

-ពិភាក្សា និងអនុម័តរបាយការណ៍ស្តីពីសភាពការណ៍ និងទិសដៅភារកិច្ចរបស់ ស.អ.ក.

-ពិភាក្សា និងអនុម័តរបាយការណ៍ស្តីពីស្ថានភាព និងផែនការហិរញ្ញវត្ថុរបស់ ស.អ.ក.

-ពិភាក្សា និងអនុម័ត ឬធ្វើការកែប្រែលក្ខន្តិកៈរបស់ ស.អ.ក.

-បោះឆ្នោតជ្រើសតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការកណ្តាល ស.អ.ក.

-ពិភាក្សា និងអនុម័តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ស្តីពីកម្មវិធីការងាររបស់ ស.អ.ក.។

ប្រការ១៦.-

សមាជិកចូលរួមមហាសន្និបាតត្រូវកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងត្រូវបានកោះអញ្ជើញជាលាយលក្ខណ៍អក្សរយ៉ាងតិច ១៥ ថ្ងៃ មុនថ្ងៃប្រជុំ ដោយត្រូវភ្ជាប់ជាមួយនូវរបៀបវារៈ និងឯកសារពាក់ព័ន្ធ ។

សមាជិកគណៈកម្មាធិការកណ្តាល ស.អ.ក. ប្រធានគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវបានផ្តល់អាទិភាពចូលរួមក្នុងមហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេស ។

តំណាងចូលរួមមហាសន្និបាតទាំងអស់ត្រូវមានសមាជិកសកម្មយ៉ាងតិច ៥០ ភាគរយ ។

ប្រការ១៧.-

មហាសន្និបាតអាចដំណើរការទៅបានតែក្នុងករណីមានសមាជិកលើសពី ៥០ភាគរយ ក្នុងចំណោមសមាជិកដែលត្រូវបានកោះអញ្ជើញចូលរួម ។

ប្រការ១៨.-

-ប្រធាន ស.អ.ក. ជាប្រធានមហាសន្និបាត ។ ប្រធាន ស.អ.ក.អាចប្រគល់សិទ្ធិឱ្យអនុប្រធាន ១រូប ដឹកនាំមហាសន្និបាតជំនួស ។

-រាល់ការអនុម័តរបស់មហាសន្និបាតត្រូវយកសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកមហាសន្និបាតទាំងមូលទើបចាត់ទុកជាបានការ ប្រសិនបើមានសម្លេងស្មើគ្នា ប្រធានមហាសន្និបាត ស.អ.ក. មានសិទ្ធិសម្រេច ។

-នីតិវិធីនៃការបោះឆ្នោតត្រូវសម្រេចដោយមហាសន្និបាត

-ចំពោះការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការកណ្តាលប្រសិនបើមានបេក្ខជនទទួលសម្លេងស្មើគ្នាត្រូវជ្រើសរើសយកបេក្ខជនដែលមានអាយុច្រើនជាងគេ ។

## ជំពូកទី៥
## ប្រធាន ស.អ.ក.

ប្រការ១៩.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាសប្រាំ ជាប្រធាន ស.អ.ក. ជាវៀងរហូតនិងជាវីរជន ជាអគ្គមគ្គុទេសក៍ដ៏ឧត្តុង្គឧត្តម និងជាទីគោរពរបស់សមាជិក ស.អ.ក. ។

## ជំពូកទី៦
## គណៈកម្មាធិការកណ្តាល ស.អ.ក.

ប្រការ២០.-

គណៈកម្មាធិការកណ្តាល ស.អ.ក. មានរចនាសម្ព័ន្ធ និងសមាសភាពដូចខាងក្រោម :

-សម្តេចប្រធាន ស.អ.ក. ជាប្រធានគណៈកម្មាធិការកណ្តាល ស.អ.ក.

-ស.អ.ក. មានអនុប្រធានមួយចំនួន ក្នុងនោះអនុប្រធានមួយរូបជាអគ្គលេខាធិការ ដែលដឹកនាំគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក.

-សមាជិកគណៈកម្មាធិការកណ្តាល ស.អ.ក. ត្រូវបានបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេសឬមហាសន្និបាតវិសាមញ្ញតំណាង ស.អ.ក. ទូទាំងប្រទេស

-លក្ខណវិនិច្ឆ័យរបស់សមាជិកគណៈកម្មាធិការកណ្តាលរួមមាន ៖

ក-ជាសមាជិកសកម្ម ឬសមាជិកកិត្តិយស ស.អ.ក.

ខ-មានសមត្ថភាពចូលរួមក្នុងការដឹកនាំ ស.អ.ក.

គ-មានលក្ខណសម្បត្តិគ្រប់គ្រាន់ និងទទួលបានការគាំទ្រពីសមាជិក ស.អ.ក. ។

ប្រការ២១.-

សមាជិកគណៈកម្មាធិការកណ្តាល ស.អ.ក. ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតរបស់មហាសន្និបាត ឬមហាសន្និបាតវិសាមញ្ញតំណាង ស.អ.ក. ទូទាំងប្រទេស ។ សម្តេចប្រធាន ស.អ.ក.

មានសិទ្ធិតែងតាំងបន្ថែមសមាជិកគណៈកម្មាធិការកណ្ដាល ស.អ.ក. ចំនួន ១ភាគ៣ នៃសមាជិកគណៈកម្មាធិការកណ្ដាលដែលជ្រើសតាំងដោយមហាសន្និបាត និងមានសិទ្ធិកែសម្រួល បំពេញបន្ថែមនូវសមាភាពគណៈកម្មាធិការកណ្ដាល តាមការស្នើសុំពីគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្ដាល ស.អ.ក. ។

ប្រការ២២.-

គណៈកម្មាធិការកណ្ដាល មានភារកិច្ចដឹកនាំអនុវត្តសេចក្ដីសម្រេចមហាសន្និបាតពីអាណត្តិមួយទៅអាណត្តិមួយទៀត ។ សមាជិកគណៈកម្មាធិការកណ្ដាលមានសិទ្ធិឈរឈ្មោះជាថ្មីក្រោយពេលផុតអាណត្តិ ។

ប្រការ២៣.-

គណៈកម្មាធិការកណ្ដាល ស.អ.ក. ត្រូវប្រជុំ ៦(ប្រាំមួយ)ខែម្ដង ឬប្រជុំជាវិសាមញ្ញតាមការអញ្ជើញរបស់អគ្គលេខាធិការក្រោយបានទទួលការឯកភាព ពីសម្ដេចប្រធានដើម្បីត្រួតពិនិត្យសកម្មភាពការងារ និងលើកទិសដៅអនុវត្តបន្ត ។

ប្រការ២៤.-

ការប្រជុំរបស់គណៈកម្មាធិការកណ្ដាល ស.អ.ក. អាចដំណើរការទៅបានតែក្នុងករណីមានសមាជិកចូលរួមយ៉ាងតិចលើសពី ៥០ ភាគរយនៃសមាជិកគណៈកម្មាធិការកណ្ដាលទាំងអស់ ។ ការសម្រេចអ្វីមួយត្រូវអនុម័តយកតាមសម្លេងភាគច្រើនដាច់ខាតនៃអ្នកចូលរួម ។ ប្រសិនបើមានសម្លេងស្មើគ្នា ប្រធានអង្គប្រជុំមានសិទ្ធិសម្រេច ។

ប្រការ២៥.-

សមាជិកគណៈកម្មាធិការកណ្ដាល ស.អ.ក. ត្រូវបម្រើការងារជូនសមាគមដោយស្ម័គ្រចិត្ត ។ ក្នុងករណីត្រូវចេញបំពេញបេសកកម្មចាំបាច់ក្នុង ឬក្រៅប្រទេស ដើម្បីប្រយោជន៍រួមរបស់ ស.អ.ក. សមាជិកអាចស្នើសុំថវិកាពីសមាគម ។

ប្រការ២៦.-

គណៈកម្មាធិការកណ្ដាល ស.អ.ក. មានសិទ្ធិប្រើប្រាស់ត្រារបស់ ស.អ.ក. ។

## ជំពូកទី៧

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល

ប្រការ២៧.-

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស.អ.ក. ត្រូវជ្រើសតាំងដោយគណៈកម្មាធិការកណ្ដាល ស.អ.ក. ក្នុងចំណោមសមាជិកគណៈកម្មាធិការកណ្ដាល ស.អ.ក. ។

ចំនួនសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស.អ.ក. មិនត្រូវលើស១ភាគ៣ នៃសមាជិកគណៈកម្មាធិការកណ្ដាល ស.អ.ក. ។

រចនាសម្ព័ន្ធគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស.អ.ក. រួមមាន អគ្គលេខាធិការ អគ្គលេខាធិការរង និងសមាជិកមួយចំនួនតាមការចាំបាច់ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ជាសេនាធិការរបស់ប្រធាន និងគណៈកម្មាធិការកណ្តាលរបស់ ស.អ.ក. ចាត់ចែងដឹកនាំអនុវត្តរាល់កិច្ចការប្រចាំថ្ងៃរបស់ ស.អ.ក. តាមសេចក្តីសម្រេចរបស់មហាសន្និបាតឬគណៈកម្មាធិការកណ្តាល ។

គណៈអចិន្ត្រៃយ៍ត្រូវកោះប្រជុំ ៣ខែម្តង ឬច្រើនជាងនេះតាមការចាំបាច់ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ត្រូវមានលេខាធិការដ្ឋាន និងគណៈជំនាញមួយចំនួនតាមការចាំបាច់ជាជំនួយការ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលមានសិទ្ធិប្រើប្រាស់ត្រារបស់ ស.អ.ក. ។

ប្រការ២៨.-

ក-អគ្គលេខាធិការមានភារកិច្ច ៖

- ចាត់ចែងការងារប្រចាំថ្ងៃរបស់ ស.អ.ក.
- ដឹកនាំលេខាធិការដ្ឋាន និងគណៈជំនាញគ្រប់គ្រងការងាររដ្ឋបាល និងមន្ត្រីបុគ្គលិកគ្រប់ថ្នាក់របស់ ស.អ.ក.
- ចុះហត្ថលេខាលើលិខិត និងឯកសាររដ្ឋបាលផ្សេងៗ
- ទាក់ទងជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងអង្គការនានា
- រៀបចំរបាយការណ៍ការងារ និងទិសដៅរបស់ ស.អ.ក. តាមការកំណត់
- ទាក់ទងជាមួយសមាគមអតីតយុទ្ធជនអន្តរជាតិ បណ្តាប្រទេសក្នុងតំបន់ និងលើពិភពលោក
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់សម្តេចប្រធាន គណៈកម្មាធិការកណ្តាល ស.អ.ក. និងគណៈអចិន្ត្រៃយ៍។

ខ-អគ្គលេខាធិការរងជាជំនួយការឲ្យអគ្គលេខាធិការ និងជូសមុខឲ្យអគ្គលេខាធិការតាមការប្រគល់ភារកិច្ច ។

## ជំពូកទី៨
## លេខាធិការដ្ឋាន និងគណៈជំនាញរបស់គណៈអចិន្ត្រៃយ៍ស.អ.ក.

ប្រការ២៩.-

ការតែងតាំង ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន និងគណៈជំនាញរបស់គណៈអចិន្ត្រៃយ៍ ស.អ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

## ជំពូកទី៩
## គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាខាឃុំ សង្កាត់

ប្រការ៣០.-

ក-សមាសភាព រចនាសម្ព័ន្ធ ចំនួនសមាជិកគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត មានចំនួនយ៉ាងតិច ៩ រូប យ៉ាងច្រើន ៣១ រូប តាមការចាំបាច់ ។

គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត មានប្រធាន ១ រូប និងអនុប្រធានមួយចំនួន តាមការចាំបាច់ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវមានចំនួនមិនលើសពី ១ភាគ៣ នៃសមាជិកគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ។

គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត អាចមានប្រធានកិត្តិយសនិងសមាជិកកិត្តិយសនៅថ្នាក់របស់ខ្លួន ។

ខ-គណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ មានចំនួនពី ៩ ទៅ ២១ រូប ដឹកនាំដោយប្រធាន ១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ ត្រូវមានចំនួនមិនលើសពី ១ភាគ៣ នៃសមាជិកគណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ ។

គ-សាខា ស.អ.ក. ឃុំ សង្កាត់ ត្រូវដឹកនាំដោយប្រធាន១រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។ សាខា ស.អ.ក. ឃុំ សង្កាត់ ត្រូវមានសមាជិក ស.អ.ក. ចាប់ពី ៧ នាក់ឡើងទៅទើបអាចបង្កើតសាខាបាន ។

ប្រការ៣១.-

គណៈកម្មាធិការ ឬគណៈអចិន្ត្រៃយ៍ ស.អ.ក. ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងក្រុមការងារជំនាញមួយចំនួនជាជំនួយការតាមការចាំបាច់ និងតាមការណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

គណៈកម្មាធិការ ស.អ.ក. នៅថ្នាក់នីមួយៗត្រូវប្រជុំ ៣ខែម្តង ឬអាចកោះប្រជុំច្រើនជាងនេះតាមការចាំបាច់ ។

ប្រការ៣២.-

សមាសភាព និងមុខតំណែងរបស់សមាជិកគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវតែងតាំងដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

ប្រធានកិត្តិយស និងសមាជិកកិត្តិយសនៃគណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវតែងតាំងដោយសម្តេចប្រធាន តាមសំណើរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស.អ.ក. ។

សមាសភាព និងមុខតំណែងរបស់សមាជិកគណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌត្រូវតែងតាំងដោយគណៈអចិន្ត្រៃយ៍ ស.អ.ក. រាជធានី ខេត្ត ។

សមាសភាព និងមុខតំណែងរបស់សាខា ស.អ.ក. ឃុំ សង្កាត់ ត្រូវតែងតាំងដោយគណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ ។

ប្រការ៣៣.-

ស.អ.ក. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបើកសន្និបាតសាមញ្ញ១ឆ្នាំម្តង និងបើកសន្និបាតវិសាមញ្ញតាមការចាំបាច់ ។

សន្និបាតមានភារកិច្ចៈ

- ពិភាក្សាអនុម័តលើកម្មវិធីការងាររបស់ ស.អ.ក. នៅថ្នាក់របស់ខ្លួន
- ពិភាក្សា អនុម័តរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៅថ្នាក់របស់ខ្លួន
- ពិភាក្សា ផ្តល់យោបល់លើលក្ខន្តិកៈ កម្មវិធីការងារ សេចក្តីសម្រេច នៃមហាសន្និបាតតំណាងទូទាំងប្រទេសរបស់ ស.អ.ក. តាមការណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក.

- ស.អ.ក. គ្រប់ថ្នាក់ត្រូវសហការឱ្យបានល្អជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី គ្រប់ថ្នាក់ ។

ប្រការ៣៤.-

ក-គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត មានភារកិច្ច ៖

- ចេញសេចក្ដីសម្រេចទទួលស្គាល់សមាជិក ស.អ.ក. ទាំងពីរប្រភេទ (គឺសមាជិកសកម្ម និងសមាជិកអកម្ម) នៅថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ចេញប័ណ្ណសមាជិក ស.អ.ក.
- ធ្វើរបាយការណ៍ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស្ដីពីស្ថានភាពសមាជិក ដោយភ្ជាប់ជាមួយនូវបញ្ជីរាយនាមសមាជិក ស.អ.ក.
- ប្រមូលប្រាក់ភាគទានសមាជិកពី ស.អ.ក. ថ្នាក់ក្រោម និងបង់ជូនថ្នាក់លើតាមកាលកំណត់
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់គ្រប់សមាជិករបស់ខ្លួននូវព័ត៌មាន ឬសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ស.អ.ក.
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាព ស.អ.ក. ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ផ្ញើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ស.អ.ក.
- គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត មានសិទ្ធិប្រើប្រាស់ត្រា ស.អ.ក. សម្រាប់ថ្នាក់របស់ខ្លួន ។

ខ-គណៈកម្មាធិការ ស.អ.ក. ក្រុង ស្រុក ខណ្ឌ សាខា ឃុំ សង្កាត់ មានភារកិច្ច ៖

- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការ ស.អ.ក. ថ្នាក់លើផ្ទាល់ស្ដីពីស្ថានភាពសមាជិក ដោយភ្ជាប់ជាមួយនូវបញ្ជីរាយនាមសមាជិក ស.អ.ក.
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់សមាជិករបស់ខ្លួននូវព័ត៌មាន ឬសេចក្ដីសម្រេចរបស់ ស.អ.ក. ថ្នាក់លើ
- ធ្វើរបាយការណ៍ ស្ដីពីសកម្មភាព ស.អ.ក. ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ផ្ញើជូន ស.អ.ក. ថ្នាក់លើ
- ទទួល និងបញ្ជូនពាក្យសុំចូលជាសមាជិកទៅ ស.អ.ក. រាជធានី ខេត្ត ដើម្បីចេញសេចក្ដីសម្រេចទទួលស្គាល់
- ក្ដាប់សភាពការណ៍ ជីវភាព របស់សមាជិក ស.អ.ក. លើកគម្រោងអភិវឌ្ឍ និងរាយការណ៍ជូន ស.អ.ក. ថ្នាក់លើ ។

## ជំពូកទី១០
## ហិរញ្ញវត្ថុរបស់ ស.អ.ក.

ប្រការ៣៥.-

ស.អ.ក. មានថវិកាដែលបានមកពីប្រភព ៖

- ភាគទាននិងវិភាគទានរបស់សមាជិក ស.អ.ក.
- អំណោយសប្បុរសធម៌របស់សប្បុរសជន អង្គការជាតិ អន្តរជាតិ
- អាជីវកម្មស្របច្បាប់របស់ ស.អ.ក.
- អំណោយរបស់រាជរដ្ឋាភិបាល ។

ប្រការ៣៦.-

អត្រាបែងចែងថវិកាភាគទានការគ្រប់គ្រង និងការប្រើប្រាស់ថវិកាភាគទាន ថវិកា និងទ្រព្យសម្បត្តិផ្សេងៗទៀតរបស់ ស.អ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

ប្រការ៣៧.-

ករណី ស.អ.ក. ឈប់ដំណើរការ ទ្រព្យសម្បត្តិរបស់ ស.អ.ក. ត្រូវប្រគល់ជូនក្រសួងទទួលបន្ទុកវិស័យអតីតយុទ្ធជន ចាត់ចែងជាផលប្រយោជន៍របស់អតីតយុទ្ធជន ។

## ជំពូកទី១១
## បេឡាមរណសង្គ្រោះ

ប្រការ៣៨.-

សមាគមអតីតយុទ្ធជនកម្ពុជាបង្កើតឲ្យមានបេឡាមរណសង្គ្រោះ ដើម្បីពង្រីកស្មារតីជួយគ្នាទៅវិញទៅមកក្នុងសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា ។ បេឡាមរណសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជាត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកដែលសម្រេចដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

ប្រការ៣៩.-

គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ត្រូវសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធនឹងវិស័យអតីតយុទ្ធជន ក្នុងការអនុវត្តលក្ខន្តិកៈបេឡាមរណសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជា។

ប្រការ៤០.-

សមាជិកសកម្ម ស.អ.ក. អាចចូលជាសមាជិកបេឡាមរណសង្គ្រោះតាមការស្ម័គ្រចិត្ត និងតាមការកំណត់នៃលក្ខន្តិកៈបេឡាមរណសង្គ្រោះរបស់សមាគមអតីតយុទ្ធជនកម្ពុជា។

## ជំពូកទី១២
## ការធ្វើអធិការកិច្ច

ប្រការ៤១.-

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ត្រូវបង្កើតគណៈអធិការកិច្ច ។ គណៈកម្មាធិការ ស.អ.ក. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារអធិការកិច្ច ។ សាខា ស.អ.ក. ឃុំ សង្កាត់ ត្រូវប្រគល់ភារកិច្ចឲ្យសមាជិកមួយចំនួនទទួលបន្ទុកការងារអធិការកិច្ច ។

ការងារអធិការកិច្ចត្រូវធ្វើជាទៀងទាត់ ១ឆ្នាំ ២ដង និងត្រូវអនុវត្តជាក់ស្តែងតាមការចាំបាច់ ។

ភារកិច្ចនៃការងារអធិការកិច្ច ត្រូវត្រួតពិនិត្យនូវការអនុវត្តលក្ខន្តិកៈ ស.អ.ក. សេចក្តីសម្រេចចិត្តមហាសន្និបាត គោលការណ៍ណែនាំរបស់ ស.អ.ក. ថ្នាក់លើ ការគ្រប់គ្រងហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ ស.អ.ក. និងដោះស្រាយពាក្យបណ្តឹងវិវាទផ្សេងៗក្នុង ស.អ.ក. ។

របាយការណ៍អធិការកិច្ច ត្រូវរាយការណ៍ជូនសន្និបាតនៃថ្នាក់នីមួយៗ និងរាយការណ៍ជូនមហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេស ។

## ជំពូកទី១៣
## ការលើកសរសើរ និងពិន័យ

ប្រការ៤២.-

សមាជិក ស.អ.ក. ឬអង្គភាព ស.អ.ក. ដែលមានស្នាដៃធ្វើឲ្យ ស.អ.ក. រីកចម្រើនត្រូវបានលើកសរសើរដោយប័ណ្ណសរសើរ លិខិតសរសើររបស់ ស.អ.ក. ។

ប្រការ៤៣.-

**ការលើកសរសើរ ៖**

ក-ចំពោះអង្គភាព ស.អ.ក. ដែលមានស្នាដៃល្អក្នុងការបំពេញការងារតាមគោលការណ៍របស់ ស.អ.ក. ត្រូវបានលើកសរសើរ និងផ្តល់រង្វាន់លើកទឹកចិត្តពី ស.អ.ក. ។

ខ-ចំពោះសមាជិក ស.អ.ក. ដែលមានស្នាដៃល្អក្នុងការបំពេញការងារតាមគោលការណ៍របស់ ស.អ.ក. ត្រូវបានលើកសរសើរ និងផ្តល់រង្វាន់លើកទឹកចិត្តពី ស.អ.ក. ។

**ការដាក់ពិន័យ ៖**

១-ចំពោះសមាជិក

ក-កម្រិតស្រាល ត្រូវទទួលការក្រើនរំលឹក ស្តីបន្ទោស ព្រមាន ដើម្បីកែប្រែឡើងវិញ។

ខ-កម្រិតធ្ងន់ត្រូវបណ្តេញចេញពី ស.អ.ក. ចំពោះសមាជិកណាដែល:

- បានប្រព្រឹត្តខុសពីលក្ខន្តិកៈ
- បានធ្វើឲ្យខូចប្រយោជន៍ ស.អ.ក. ។

២-ចំពោះអង្គភាព ស.អ.ក.

ក-កម្រិតស្រាល ត្រូវទទួលការក្រើនរំលឹក ស្តីបន្ទោស ព្រមាន

ខ-កម្រិតធ្ងន់ ត្រូវរំសាយនិងរៀបចំសមាសភាពឡើងវិញ ។

ប្រការ៤៤.-

**សមត្ថកិច្ចលើកសរសើរ និងដាក់ពិន័យ:**

ការលើកសរសើរ ការដាក់ពិន័យ ចំពោះសមាជិក ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាលើកសរសើរជូនរង្វាន់ និងពិន័យរបស់ ស.អ.ក. គ្រប់ថ្នាក់ ។ ស.អ.ក. គ្រប់ថ្នាក់ត្រូវបង្កើតក្រុមប្រឹក្សា លើកសរសើរ ជូនរង្វាន់ និងពិន័យ ។

សេចក្តីសម្រេចក្នុងការបណ្តេញសមាជិក ស.អ.ក. ត្រូវធ្វើដោយគណៈកម្មាធិការ ស.អ.ក. ដែលចេញសេចក្តីសម្រេចទទួលស្គាល់សមាជិកភាព ។

លិខិតសរសើរ និងប័ណ្ណសរសើររបស់ ស.អ.ក. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស.អ.ក. ។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

ប្រការ៤៥.-

បុគ្គលទាំងឡាយណាដែលបានចូលជាសមាជិក ស.អ.ក. មុនការអនុម័តកែប្រែលក្ខន្តិកៈនេះ នៅរក្សាសិទ្ធិ កាតព្វកិច្ច និងអត្ថប្រយោជន៍នានាដែលបានទទួលកន្លងមក ។

បុគ្គលទាំងឡាយណាដែលបានចូលជាសមាជិកបេឡាមរណសង្គ្រោះមុនការអនុម័តកែប្រែលក្ខន្តិកៈនៅទទួលបានអត្ថប្រយោជន៍នៃបេឡាមរណសង្គ្រោះដដែល ប៉ុន្តែអត្ថប្រយោជន៍នេះពុំអាចផ្ទេរបន្តទៅទាយាទរបស់ខ្លួនឡើយ ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

ប្រការ៤៦.-

មានតែមហាសន្និបាតតំណាង ស.អ.ក. ទូទាំងប្រទេស ទើបមានសិទ្ធិរំលាយ ស.អ.ក.។ ក្នុងករណីនេះ មហាសន្និបាតអាចដំណើរការទៅបាន លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច៣ភាគ៤ នៃសមាជិកដែលត្រូវបានអញ្ជើញចូលរួម ហើយការអនុម័តត្រូវយកសំឡេងយ៉ាងតិច៣ភាគ៤នៃសមាជិកដែលបានចូលរួមក្នុងមហាសន្និបាត ។

ប្រការ៤៧.-

មានតែមហាសន្និបាត ឬមហាសន្និបាតវិសាមញ្ញតំណាង ស.អ.ក. ទូទាំងប្រទេសទើបអាចសម្រេចអនុម័ត ឬកែប្រែលក្ខន្តិកៈនេះបាន ។

ប្រការ៤៨.-

លក្ខន្តិកៈនេះត្រូវបានកែប្រែ និងអនុម័តដោយមហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស លើកទី២ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ និងចូលជាធរមានចាប់ពីកាលបរិច្ឆេទអនុម័តតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៥

**ជ.គណៈកម្មាធិការកណ្តាលសមាគមអតីតយុទ្ធជនកម្ពុជា**

**ប្រធាន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# រចនាសម្ព័ន្ធ
# សមាគមអតីតយុទ្ធជនកម្ពុជា

**មហាសន្និបាត ឬមហាសន្និបាតវិសាមញ្ញ**
**តំណាង ស.អ.ក. ទូទាំងប្រទេស**

↓

**គណៈកម្មាធិការកណ្តាល**
**ប្រធាន**
**អនុប្រធាន**
**គណៈអចិន្ត្រៃយ៍**
**អគ្គលេខាធិការ**

↓ — **-លេខាធិការដ្ឋាន**
**-គណៈជំនាញ**

**គណៈកម្មាធិការ រាជធានី ខេត្ត**

↓ — **ក្រុមការងារជំនាញ**

**គណៈកម្មាធិការ ក្រុង ស្រុក ខណ្ឌ**

↓ — **ក្រុមការងារជំនាញ**

**សាខាឃុំ សង្កាត់**

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៥

**ជ.គណៈកម្មាធិការកណ្តាលសមាគមអតីតយុទ្ធជនកម្ពុជា**
**ប្រធាន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ស្លាកសញ្ញាសមាគមអតីតយុទ្ធជនកម្ពុជា

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥

**ឋ.គណៈកម្មាធិការកណ្តាលសមាគមអតីតយុទ្ធជនកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**